ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
លេខ...០០៧.......សហវ.......

# សេចក្តីណែនាំ
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធអេហ្វអឹមអាយអេស (FMIS) នៅរដ្ឋបាលរាជធានី-ខេត្ត និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្តាលសម្រាប់ឆ្នាំ ២០២២

ស្របតាមផែនការរួមដំណាក់កាលទី ៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា និង ផែនការពង្រីកការប្រើប្រាស់ប្រព័ន្ធ FMIS ជំហានទី ២ (២០១៧-២០២០), ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំ និង ដាក់ឱ្យដំណើរការរួចជាស្រេចនូវប្រព័ន្ធ FMIS នៅគ្រប់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុក្រសួង-ស្ថាប័ន, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្តាល, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តទាំង ២៥ និង រតនាគាររាជធានីខេត្តទាំង ២៥ គិតត្រឹមឆ្នាំ ២០២០ កន្លងទៅនេះ ។

អនុវត្តតាមផែនការរួមដំណាក់កាលទី ៣+២ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥ និង ផែនការពង្រីកការអនុវត្តគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជំហានទី ៣ ឆ្នាំ ២០២១-២០២៥, **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបន្តពង្រីកការប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការនៅដើមឆ្នាំ ២០២២ នេះទៅដល់ ១-អង្គភាពទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុនៃរដ្ឋបាលរាជធានី-ខេត្តទាំងអស់ និង ២-អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញបន្ថែមថ្មីចំនួន ១០ នៅថ្នាក់កណ្តាលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** លើមុខងាររបស់ប្រព័ន្ធ FMIS ចំនួន ៤ រួមមាន ១-មុខងារវិភាជន៍ថវិកា, ២-មុខងារការទិញ, ៣-មុខងារគណនីត្រូវសង និង ចំណាយថវិកា និង ៤-មុខងារគណនីត្រូវទារ និង ចំណូលថវិកា ។

ជាមួយនឹងការពង្រីកការប្រើប្រាស់ប្រព័ន្ធ FMIS ខាងលើនេះ, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត និង អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុដែលកំពុងតែប្រើប្រាស់ប្រព័ន្ធ FMIS នៃក្រសួងអាណាប័កដើមខ្សែរបស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញទាំង ១០ ក៏នឹងមានការផ្លាស់ប្តូរមួយចំនួនលើការប្រើប្រាស់ប្រព័ន្ធ FMIS ផងដែរ ។ សម្រាប់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញបន្ថែមថ្មីទាំង ១០ គឺសុទ្ធសឹងជាអង្គភាពថវិកាដែលស្ថិតនៅក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមមាន ១-អគ្គនាយកដ្ឋានគោលនយោបាយ, ២-អគ្គនាយកដ្ឋានថវិកា, ៣-អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, ៤-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ, ៥-អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ, ៦-អគ្គាធិការដ្ឋាន, ៧-អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង, ៨-អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង គ្រប់គ្រងបំណុល, ៩-អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ និង ១០-វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ដើម្បីឱ្យការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ខាងលើមានដំណើរការប្រកបដោយប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចតទៅ÷

## គ. ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS នៅរដ្ឋបាលរាជធានី-ខេត្តទាំងអស់

### ១. ការធ្វើចលនាឥណទានថវិកា និង តារាងរជ្ជទេយ្យបុរេប្រទាន (ប្រើប្រាស់មុខងារវិភាជន៍ថវិកា)

-រដ្ឋបាលរាជធានី-ខេត្ត ត្រូវធ្វើការកត់ត្រាប្រតិបត្តិការនិយ័តភាពឥណទានថវិកាផ្ទៃក្នុង និង ប្រតិបត្តិការបង្កើត ឬ កែតម្រូវតារាងរជ្ជទេយ្យបុរេប្រទានដែលជារបស់រដ្ឋបាលរាជធានី-ខេត្តផ្ទាល់ នៅក្នុងប្រព័ន្ធ FMIS បន្ទាប់ពីរៀបចំឯកសារនៃប្រតិបត្តិការនីមួយៗរួចរាល់ និង ត្រូវធ្វើការពិនិត្យនិងអនុម័តនៅក្នុងប្រព័ន្ធបន្ទាប់ពីបញ្ចប់ការអនុម័តលើឯកសារនីមួយៗនៅត្រឹមរដ្ឋបាលរាជធានី-ខេត្ត ។ សម្រាប់ប្រតិបត្តិការណាដែលមិនទាន់បញ្ចប់នៅត្រឹមរដ្ឋបាលរាជធានី-ខេត្ត, ប្រព័ន្ធ FMIS នឹងបញ្ជូនដោយស្វ័យប្រវត្តិទៅកាន់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

-មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី-ខេត្ត មិនមានការកត់ត្រាប្រតិបត្តិការនិយ័តភាពឥណទានថវិកាផ្ទៃក្នុង និង ប្រតិបត្តិការបង្កើត ឬ កែតម្រូវតារាងរជ្ជទេយ្យបុរេប្រទានរបស់រដ្ឋបាលរាជធានី-ខេត្តទៀតទេ ប៉ុន្តែត្រូវធ្វើការត្រួតពិនិត្យនិងអនុម័តប្រតិបត្តិការបង្កើត ឬ កែតម្រូវតារាងរជ្ជទេយ្យបុរេប្រទានរបស់រដ្ឋបាលរាជធានី-ខេត្តនៅក្នុងប្រព័ន្ធ FMIS បន្ទាប់ពីទទួលបានឯកសារតារាងរជ្ជទេយ្យបុរេប្រទានពីរដ្ឋបាលរាជធានី-ខេត្ត ។ ប្រតិបត្តិការដែលត្រូវបញ្ជូនបន្តទៅកាន់រតនាគាររាជធានី-ខេត្តប្រព័ន្ធ FMIS នឹងបញ្ជូនដោយស្វ័យប្រវត្តិ ។

### ២. សំណើសុំធានាចំណាយ និង កិច្ចលទ្ធកម្ម (ប្រើប្រាស់មុខងារការទិញ)

-រដ្ឋបាលរាជធានី-ខេត្ត ត្រូវធ្វើការកត់ត្រាប្រតិបត្តិការស្នើសុំធានាចំណាយកិច្ចលទ្ធកម្ម (Requisition), ប្រតិបត្តិការស្នើសុំធានាចំណាយមិនមែនកិច្ចលទ្ធកម្ម (PO-GEN), ប្រតិបត្តិការស្នើសុំធានាចំណាយបុរេប្រទាន (PO-ADV), ប្រតិបត្តិការកិច្ចលទ្ធកម្ម (PO-P2P) និង ប្រតិបត្តិការកិច្ចការប្រគល់ទទួល (PO-GRN) របស់ខ្លួននៅក្នុងប្រព័ន្ធ FMIS នៅពេលបន្ទាប់ពីរៀបចំ ឬ ទទួលបានឯកសារនៃប្រតិបត្តិការនីមួយៗរួចរាល់ និង ត្រូវធ្វើការពិនិត្យនិងអនុម័តនៅក្នុងប្រព័ន្ធបន្ទាប់ពីបញ្ចប់ការអនុម័តលើឯកសារនីមួយៗនៅត្រឹមរដ្ឋបាលរាជធានី-ខេត្ត ។ ប្រព័ន្ធ FMIS នឹងបញ្ជូនប្រតិបត្តិការទាំងនោះបន្តដោយស្វ័យប្រវត្តិទៅកាន់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លើកលែងតែប្រតិបត្តិការកិច្ចលទ្ធកម្ម (PO-P2P) ករណីលើសសិទ្ធិសម្រេច, ប្រព័ន្ធ FMIS នឹងបញ្ជូនប្រតិបត្តិការនោះទៅកាន់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដូចការអនុវត្តបច្ចុប្បន្ន ។

-មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី-ខេត្ត មិនមានការកត់ត្រាប្រតិបត្តិការស្នើសុំធានាចំណាយកិច្ចលទ្ធកម្ម (Requisition), ប្រតិបត្តិការស្នើសុំធានាចំណាយមិនមែនកិច្ចលទ្ធកម្ម (PO-GEN) និង ប្រតិបត្តិការស្នើសុំធានាចំណាយបុរេប្រទាន (PO-ADV) របស់រដ្ឋបាលរាជធានី-ខេត្តទៀតទេ ប៉ុន្តែត្រូវធ្វើការត្រួតពិនិត្យនិងអនុម័តប្រតិបត្តិការទាំងនោះនៅក្នុងប្រព័ន្ធ FMIS បន្ទាប់ពីទទួលបានឯកសារនៃប្រតិបត្តិការនីមួយៗពីរដ្ឋបាលរាជធានី-ខេត្ត ។

### ៣. ការទូទាត់ចំណាយថវិកា (ប្រើប្រាស់មុខងារគណនីត្រូវសង និង ចំណាយថវិកា)

-រដ្ឋបាលរាជធានី-ខេត្ត ត្រូវធ្វើការកត់ត្រាប្រតិបត្តិការចំណាយថវិកា (Regular Voucher) របស់ខ្លួននៅក្នុងប្រព័ន្ធ FMIS តាមរយៈឯកសារអាណត្តិបើកប្រាក់ដែលបានរៀបចំរួច និង ត្រូវធ្វើការត្រួតពិនិត្យនិងអនុម័តនៅក្នុងប្រព័ន្ធបន្ទាប់ពីអាណត្តិបើកប្រាក់នោះត្រូវបានអនុម័តរួចរាល់នៅត្រឹមរដ្ឋបាលរាជធានី-ខេត្ត ។ ប្រព័ន្ធ FMIS នឹងបញ្ជូនបន្តប្រតិបត្តិការចំណាយថវិកាដោយស្វ័យប្រវត្តិទៅមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី-ខេត្ត ។

-មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី-ខេត្ត មិនមានការកត់ត្រាប្រតិបត្តិការចំណាយថវិការបស់រដ្ឋបាលរាជធានី-ខេត្តទៀតទេ ប៉ុន្តែត្រូវធ្វើការត្រួតពិនិត្យនិងអនុម័តប្រតិបត្តិការនោះនៅក្នុងប្រព័ន្ធ FMIS បន្ទាប់ពីទទួលបានអាណត្តិបើកប្រាក់ពីរដ្ឋបាលរាជធានី-ខេត្ត ។ ប្រព័ន្ធ FMIS នឹងបញ្ជូនប្រតិបត្តិការចំណាយថវិកាដោយស្វ័យប្រវត្តិទៅកាន់រតនាគាររាជធានី-ខេត្ត ។

**៤.ការផ្ទេរចំណូលថវិកា (ប្រើប្រាស់មុខងារគណនីត្រូវទារ និង ចំណូលថវិកា)**

-រដ្ឋបាលរាជធានី-ខេត្ត ត្រូវធ្វើការកត់ត្រាប្រតិបត្តិការបង្វែរចំណូលថវិការបស់ខ្លួននៅក្នុងប្រព័ន្ធ FMIS តាមរយៈឯកសារសលាកបត្របង្វែរចំណូលថវិកា ក្នុងករណីចំណូលថវិកានោះមិនទាន់ធ្វើសន្ទានកម្មជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) និង ត្រូវធ្វើការត្រួតពិនិត្យនិងអនុម័តនៅក្នុងប្រព័ន្ធបន្ទាប់ពីសលាកបត្របង្វែរចំណូលថវិកាត្រូវបានអនុម័តរួចរាល់នៅត្រឹមរដ្ឋបាលរាជធានី-ខេត្ត ។ ប្រព័ន្ធ FMIS នឹងបញ្ជូនបន្តប្រតិបត្តិការចំណូលថវិកាទៅរតនាគាររាជធានី-ខេត្តដោយស្វ័យប្រវត្តិ ។

-រតនាគាររាជធានី-ខេត្ត មិនមានការកត់ត្រាប្រតិបត្តិការចំណូលថវិការបស់រដ្ឋបាលរាជធានី-ខេត្តទៀតទេ ប៉ុន្តែត្រូវធ្វើការត្រួតពិនិត្យនិងអនុម័តប្រតិបត្តិការនោះនៅក្នុងប្រព័ន្ធ FMIS បន្ទាប់ពីទទួលបានសលាកបត្របង្វែរចំណូលពីរដ្ឋបាលរាជធានី-ខេត្ត ។

**ខ. ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS នៅអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១០**

**១.ការធ្វើចលនាឥណទានថវិកា និង តារាងរជ្ជទេយ្យបុរេប្រទាន (ប្រើប្រាសមុខងារវិភាជន៍ថវិកា)**

អង្គភាពថវិកាទាំង ១០ ត្រូវធ្វើការកត់ត្រាប្រតិបត្តិការនិយ័តភាពឥណទានថវិកាផ្ទៃក្នុង និង ប្រតិបត្តិការបង្កើត ឬ កែតម្រូវតារាងរជ្ជទេយ្យបុរេប្រទានដែលជារបស់ខ្លួនផ្ទាល់ នៅក្នុងប្រព័ន្ធ FMIS បន្ទាប់ពីរៀបចំឯកសារនៃប្រតិបត្តិការនីមួយៗរួចរាល់ និង ត្រូវធ្វើការពិនិត្យនិងអនុម័តនៅក្នុងប្រព័ន្ធបន្ទាប់ពីបញ្ចប់ការអនុម័តលើឯកសារនីមួយៗនៅត្រឹមអង្គភាពថវិកា ។ ប្រព័ន្ធ FMIS នឹងបញ្ជូនប្រតិបត្តិការពាក់ព័ន្ធនឹងការបង្កើត ឬ កែតម្រូវរជ្ជទេយ្យបុរេប្រទានទៅកាន់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងដោយស្វ័យប្រវត្តិ ។ ដោយឡែក អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មិនមានការកត់ត្រាប្រតិបត្តិការដែលអង្គភាពថវិកាទាំង ១០ ខាងលើកត់ត្រានោះទៀតទេ ។

**២.សំណើធានាចំណាយ និង កិច្ចលទ្ធកម្ម (ប្រើប្រាស់មុខងារការទិញ)**

-ពាក់ព័ន្ធនឹងសំណើធានាចំណាយ អង្គភាពថវិកា ត្រូវធ្វើការកត់ត្រាប្រតិបត្តិការស្នើសុំធានាចំណាយកិច្ចលទ្ធកម្ម (Requisition) ករណីក្រោមសិទ្ធិសម្រេច, ប្រតិបត្តិការស្នើសុំធានាចំណាយមិនមែនកិច្ចលទ្ធកម្ម (PO-GEN) និង ប្រតិបត្តិការស្នើសុំធានាចំណាយបុរេប្រទាន (PO-ADV) របស់ខ្លួននៅក្នុងប្រព័ន្ធ FMIS នៅពេលបន្ទាប់ពីរៀបចំ ឬ ទទួលបានឯកសារនៃប្រតិបត្តិការនីមួយៗរួចរាល់ និង ត្រូវធ្វើការពិនិត្យនិងអនុម័តនៅក្នុងប្រព័ន្ធបន្ទាប់ពីបញ្ចប់ការអនុម័តលើឯកសារនីមួយៗនៅត្រឹមអង្គភាពថវិកាផ្ទាល់ខ្លួន ។ ប្រព័ន្ធ FMIS នឹងបញ្ជូនប្រតិបត្តិការទាំងនោះបន្តដោយស្វ័យប្រវត្តិទៅកាន់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ សម្រាប់ប្រតិបត្តិការស្នើសុំធានាចំណាយកិច្ចលទ្ធកម្ម (Requisition) ករណីលើសសិទ្ធិសម្រេចរបស់អង្គភាពថវិកា គឺនៅអនុវត្តដូចបច្ចុប្បន្ន ។ ដោយឡែក អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មិនមានការកត់ត្រាប្រតិបត្តិការស្នើសុំធានាចំណាយកិច្ចលទ្ធកម្ម (Requisition) ករណីក្រោមសិទ្ធិសម្រេច, ប្រតិបត្តិការស្នើសុំធានាចំណាយមិនមែនកិច្ចលទ្ធកម្ម (PO-GEN) និង ប្រតិបត្តិការស្នើសុំធានាចំណាយបុរេប្រទាន (PO-ADV) របស់អង្គភាពថវិកាទាំង ១០ ទៀតទេ ។

-ពាក់ព័ន្ធនឹងកិច្ចលទ្ធកម្ម អង្គភាពថវិកា ត្រូវធ្វើការកត់ត្រាប្រតិបត្តិការកិច្ចលទ្ធកម្ម (PO-P2P) និង ប្រតិបត្តិការកិច្ចការប្រគល់ទទួល (PO-GRN) របស់ខ្លួននៅក្នុងប្រព័ន្ធ FMIS សម្រាប់ករណីលទ្ធកម្មក្រោមសិទ្ធិ និង ត្រូវធ្វើការត្រួតពិនិត្យនិងអនុម័តនៅក្នុងប្រព័ន្ធដើម្បីបញ្ចប់ ។ សម្រាប់ប្រតិបត្តិការកិច្ចលទ្ធកម្ម (PO-P2P) ករណីលើសសិទ្ធិសម្រេច គឺនៅអនុវត្តដូចបច្ចុប្បន្ន ។ ដោយឡែក អង្គភាពលទ្ធកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មិនមានការកត់ត្រាប្រតិបត្តិការពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មក្រោមសិទ្ធិដែលអង្គភាពថវិកាបានកត់ត្រារួចហើយនោះទេ ។

**៣. ការទូទាត់ចំណាយថវិកា (ប្រើប្រាស់មុខងារគណនីត្រូវសង និង ចំណាយវិកា)**

អង្គភាពថវិកា ត្រូវធ្វើការកត់ត្រាប្រតិបត្តិការចំណាយថវិកា (Regular Voucher) របស់ខ្លួននៅក្នុងប្រព័ន្ធ FMIS តាមរយៈឯកសារអាណត្តិបើកប្រាក់ដែលបានរៀបចំរួច និង ត្រូវធ្វើការត្រួតពិនិត្យនិងអនុម័តនៅក្នុងប្រព័ន្ធបន្ទាប់ពីអាណត្តិបើកប្រាក់នោះត្រូវបានអនុម័តរួចរាល់នៅត្រឹមអង្គភាពថវិកា ។ ប្រព័ន្ធ FMIS នឹងបញ្ជូនបន្តប្រតិបត្តិការចំណាយថវិកាដោយស្វ័យប្រវត្តិទៅមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ដោយឡែក អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មិនមានការកត់ត្រាប្រតិបត្តិការចំណាយថវិកាដែលអង្គភាពថវិកាទាំង ១០ ខាងលើកត់ត្រានោះទៀតទេ ។

**៤. ការផ្ទេរចំណូលថវិកា (ប្រើប្រាស់មុខងារគណនីត្រូវទារ និង ចំណូលថវិកា)**

អង្គភាពថវិកា ត្រូវធ្វើការកត់ត្រាប្រតិបត្តិការបង្វែរចំណូលថវិការបស់ខ្លួននៅក្នុងប្រព័ន្ធ FMIS តាមរយៈឯកសារសលាកបត្របង្វែរចំណូលថវិកា ក្នុងករណីចំណូលថវិកានោះមិនទាន់បានធ្វើសន្ធានកម្មជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) និង ត្រូវធ្វើការត្រួតពិនិត្យនិងអនុម័តនៅក្នុងប្រព័ន្ធបន្ទាប់ពីសលាកបត្របង្វែរចំណូលថវិកាត្រូវបានអនុម័តរួចរាល់នៅត្រឹមអង្គភាពថវិកា ។ ប្រព័ន្ធ FMIS នឹងបញ្ជូនបន្តប្រតិបត្តិការចំណូលថវិកាទៅអគ្គនាយកដ្ឋានរតនាគារជាតិដោយស្វ័យប្រវត្តិ ។ ដោយឡែក អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មិនមានការកត់ត្រាប្រតិបត្តិការដែលអង្គភាពថវិកាទាំង ១០ ខាងលើកត់ត្រានោះទៀតទេ ។

រដ្ឋបាលរាជធានី-ខេត្ត, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត, រតនាគាររាជធានី-ខេត្ត, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញទាំង ១០ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, អង្គភាពលទ្ធកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង អង្គភាពពាក់ព័ន្ធទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃចន្ទ ៧រោច ខែបុស្ស ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

“ដើម្បីគោរពជូនជ្រាប”

-រដ្ឋបាលរាជធានី-ខេត្ត

-អង្គភាពថវិកាទាំង ១០ នៅក្នុងសេចក្តីជូនដំណឹង

-អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-អង្គភាពលទ្ធកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត

-រតនាគាររាជធានី-ខេត្ត

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

“ដើម្បីអនុវត្ត”

-ឯកសារ -កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ខុទ្ទកាល័យ ក.ស.ហ.វ.
ចូលថ្ងៃទី 13/01/22 ម៉ោង..........
លេខ: KM2200246

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន**
**សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
លេខ......០០៨............

*ថ្ងៃ ច័ន្ទ ៨កើត ខែ បុស្ស ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥*

*រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០២២*

**សូមគោរពជូន**

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**កម្មវត្ថុ ÷** សំណើសុំគោលការណ៍ឯកភាព និង ចុះហត្ថលេខាដ៏ខ្ពង់ខ្ពស់លើសេចក្តីណែនាំស្តីពី ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធអេហ្វអឹមអាយអេស (FMIS) នៅរដ្ឋបាលរាជធានី-ខេត្ត និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្តាលសម្រាប់ឆ្នាំ ២០២២ ។

**ភ្ជាប់ជូន÷** សេចក្តីព្រាងសេចក្តីណែនាំស្តីពី ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធអេហ្វអឹមអាយអេស (FMIS) នៅរដ្ឋបាលរាជធានី-ខេត្ត និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១០ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

សេចក្តីដូចមានក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមអនុញ្ញាតគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយក-រដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា កន្លងមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំ និង ដាក់ឱ្យដំណើរការប្រព័ន្ធ FMIS នៅគ្រប់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុក្រសួង-ស្ថាប័ន, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្តាល, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តទាំង ២៥ និង រតនាគាររាជ-ធានីខេត្តទាំង ២៥ ជាផ្លូវការរួចរាល់ ។ ស្របតាមផែនការពង្រីកការអនុវត្តគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជំហានទី៣ ក្រុមការងារគ្រប់គ្រងគម្រោង FMIS បានរៀបចំសិក្សា និង ដំឡើងបណ្តាញតភ្ជាប់, ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និង មិនមែនបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងបានរៀបចំការបណ្តុះបណ្តាលលើការប្រើប្រាស់ និង មុខងារស្នូលនៃប្រព័ន្ធ FMIS ដល់ថ្នាក់ដឹកនាំ និង មន្ត្រីនៅរដ្ឋបាលរាជធានី-ខេត្ត និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១០ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការត្រៀមប្រើប្រាស់ជាផ្លូវការក្នុងឆ្នាំ ២០២២ រួចរាល់ផងដែរ ។ ដើម្បីឱ្យការអនុវត្តផែនការពង្រីកការអនុវត្តគម្រោងប្រព័ន្ធFMIS ទទួលបានជោគជ័យជាសារវ័ន្ត ក្រុមការងារគ្រប់គ្រងគម្រោង FMIS បានរៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពី ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធអេហ្វអឹមអាយអេស (FMIS) នៅរដ្ឋបាលរាជធានី-ខេត្ត និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្តាលសម្រាប់ឆ្នាំ ២០២២ និងសូមអនុញ្ញាតគោរពស្នើសុំការឯកភាពជាគោលការណ៍ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** និង ចុះហត្ថលេខាដ៏ខ្ពង់ខ្ពស់លើសេចក្តីណែនាំដូចបានគោរពជូនភ្ជាប់ ដើម្បីផ្សព្វផ្សាយនិងចាប់ផ្តើមអនុវត្តពីឆ្នាំ ២០២២ នេះតទៅ ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និង ចុះហត្ថលេខា ឬ ផ្តល់ការណែនាំជាយថាហេតុដ៏ខ្ពង់ខ្ពស់ ។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**រដ្ឋលេខាធិការ និង ជា**
**ប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS**

បណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប**

ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666